## I. សេចក្តីផ្តើម និង វិសាលភាព

១. របាយការណ៍នេះ ត្រូវបានបញ្ជូនស្របតាមសេចក្តីសំរេចចិត្តលេខ១៨/២៥ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១១ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ គឺជាការវាយតំលៃអំពីផលប៉ះពាល់សិទ្ធិមនុស្សដោយសម្បទានដីសេដ្ឋកិច្ច (ELCs) និងសម្បទានដីដទៃទៀត និងគម្រោងអភិវឌ្ឍន៍ធំៗនៅកម្ពុជា (ជាទូទៅគឺនិយាយសំដៅលើ "សម្បទានដី" នៅក្នុងរបាយការណ៍នេះទាំងមូល លុះត្រាមានការបញ្ជាក់ដោយលែក)។ របាយការណ៍នេះ មិនត្រឹមតែជាការវិភាគទៅលើសម្បទានទាក់ទងនឹងវិស័យកសិ-ឧស្សាហកម្ម (មានជាអាទិ៍ ចំការកៅស៊ូ ចំការអំពៅ ចំការម៉ៃសាក់ និងចំការដំឡូងមី) ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការវិភាគទៅលើសម្បទានរ៉ែ ប្រេងកាត និងឧស្ម័ន ព្រៃឈើ និងសម្បទានសំរាប់គោលដៅទេសចរណ៍ ការអភិវឌ្ឍន៍អចលនទ្រព្យ និងគម្រោងអភិវឌ្ឍន៍ទ្រង់ទ្រាយធំមួយចំនួន មានដូចជា ទំនប់វារីអគ្គិសនី ជាដើម។

២. ចាប់តាំងពីពេលខ្ញុំចូលកាន់មុខតំណែងជាអ្នករាយការណ៍ពិសេសក្នុងឆ្នាំ២០០៩ មក ខ្ញុំបានទទួលព័ត៌មានជាហូរហែរអំពីបញ្ហាសិទ្ធិមនុស្សទាក់ទងនឹងសម្បទានដី រាប់ទាំងការបណ្តេញចេញដោយបំពាន ការតាំងទីលំនៅថ្មី និងការផ្លាស់ទីលំនៅគ្មានផែនការច្បាស់លាស់ ការបំផ្លាញបរិស្ថាន និងការធ្វើអាជីវកម្មធនធានធម្មជាតិដែលគ្មាននិរន្តរភាព និង ការគំរាមកំហែងដល់ការចិញ្ចឹមជីវិតរបស់ជនជាតិដើមភាគតិច ប្រពៃណី និងវប្បធម៌ ក្នុងចំណោមបញ្ហាជាច្រើនទៀត។ ចំនួនករណីបណ្តឹងមានការកើនឡើងដែលខ្ញុំបានដឹងផងដែរ ដែលក្នុងនោះមានបុគ្គល និងសហគមន៍ជាច្រើនកំពុងតែធ្វើការទាមទារសិទ្ធិលើដីធ្លីរបស់ខ្លួន សកម្មជនដីធ្លី និងអ្នកការពារសិទ្ធិមនុស្សដទៃទៀត ត្រូវបានគេយាយីរំខាន គំរាមកំហែង ឬដាក់ទោសព្រហ្មទណ្ឌដោយសារតែពួកគេធ្វើការតវ៉ាចំពោះការផ្តល់ និងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀត។ ខ្ញុំបានតាមឃ្លាំមើលបញ្ហាទាំងនេះពេញអាណត្តិការងាររបស់ខ្ញុំ និងបានមានឱកាសជួបដោយផ្ទាល់ជាមួយប្រជាពលរដ្ឋទាំងឡាយដែលរងការប៉ះពាល់ ឬអ្នកបានដឹងឮអំពីសម្បទានដីទាំងនេះ នៅក្នុងអំឡុងពេលបំពេញបេសកកម្មចំនួនប្រាំពីរលើករបស់ខ្ញុំមកកាន់ប្រទេសកម្ពុជា។ ខ្ញុំបានលើកឡើងអំពីបញ្ហាទាំងនេះ នៅគ្រប់របាយការណ៍របស់ខ្ញុំដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ នៅក្នុងលិខិតរបស់ខ្ញុំផ្ញើជូនរាជរដ្ឋាភិបាលកម្ពុជា និងក្នុងកិច្ចសន្ទនារបស់ខ្ញុំជាមួយតំណាងនានារបស់រដ្ឋាភិបាល នៅក្នុងអំឡុងពេលបំពេញបេសកកម្មរបស់ខ្ញុំមកកាន់ប្រទេសកម្ពុជា។

៣. ដោយសារភាពធ្ងន់ធ្ងរ និងភាពស្រួចស្រាវនៃបញ្ហាប្រឈមនេះ និងការងារដ៏ច្រើនដែលបុព្វាធិការីរបស់ខ្ញុំបានធ្វើលើបញ្ហាសម្បទានដីសេដ្ឋកិច្ច ខ្ញុំបានផ្តោតនៅក្នុងដំណើរទស្សនកិច្ចរបស់ខ្ញុំមកកាន់ប្រទេសកម្ពុជាក្នុងខែឧសភា ឆ្នាំ២០១២ លើសម្បទានដី និងបង្ហាញរបាយការណ៍នេះជូនក្រុមប្រឹក្សាសិទ្ធិមនុស្សជាឧបសម្ព័ន្ធនៃរបាយការណ៍គោលរបស់ខ្ញុំសំរាប់ឆ្នាំ២០១១-២០១២ ដែលបានផ្តោតលើកំណែទម្រង់ប្រព័ន្ធបោះឆ្នោត។ គោលបំណងគឺដើម្បីពិនិត្យមើលស្ថានការណ៍វិវត្តន៍ថ្មីៗ អំពីបញ្ហាប្រឈមខាងសិទ្ធិមនុស្សដែលកើតចេញពីសម្បទានដី នៅចំពោះមុខសន្ទុះនៃកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនសម្បទានដីដែលបានផ្តល់អោយក្រុមហ៊ុនជាតិ និងក្រុមហ៊ុនបរទេស និងផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងររបស់សម្បទានដីទាំងនេះដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា។ ដូច្នេះ របាយការណ៍នេះដកស្រង់ផងដែរពីរបាយការណ៍ចំនួនពីរស្តីពីសម្បទានដីដែលបុព្វាធិការីរបស់ខ្ញុំពីររូប គឺតំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ (SRSG) ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានធ្វើនាពេលកន្លងមក ក្នុងឆ្នាំ២០០៤ និងឆ្នាំ២០០៧។ ទោះជាយ៉ាងណាក៏ដោយ ដោយសាររបាយការណ៍កន្លងមក បានផ្តោតជាចម្បងលើសម្បទានដីសំរាប់គោលដៅកសិកម្ម ដូច្នេះរបាយការណ៍នេះ គ្របដណ្តប់លើបញ្ហាសិទ្ធិមនុស្សទូទៅ ទាក់ទងនឹងសម្បទានដីសម្រាប់គោលដៅកសិកម្មក៏ដូចជាប្រភេទដទៃទៀតនៃសម្បទានដី ហើយក្នុងនោះមានបញ្ហាខ្លះ គឺជា

បញ្ហាថ្មី។ ខ្ញុំសូមហៅរបាយការណ៍និមួយៗនៃរបាយការណ៍ទាំងពីរកន្លងមកនេះថា "របាយការណ៍តំណាងពិសេសឆ្នាំ២០០៤" និង "របាយការណ៍តំណាងពិសេសឆ្នាំ២០០៧" នៅក្នុងរបាយការណ៍នេះទាំងមូល។ របាយការណ៍នេះមានបញ្ចូលការវិភាគដែលទាក់ទងនឹងផលប៉ះពាល់ទូទៅលើសិទ្ធិមនុស្ស ដោយសារតែការផ្តល់និង ការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀតទាំងនៅតំបន់ទីប្រជុំជន និងនៅតំបន់ជនបទ។ ទោះជាយ៉ាងណាក៏ដោយ ពីព្រោះតែកង្វល់អំពីការបំផ្លាញធនធានធម្មជាតិនៅកម្ពុជានៅតែមានជាបន្ត ខ្ញុំបានសំរេចផ្តោតការយកចិត្តទុកដាក់ជាពិសេសលើសម្បទានដីនៅក្នុងតំបន់ការពារធម្មជាតិ នៅក្នុងរបាយការណ៍នេះ (សូមមើលឧបសម្ព័ន្ធ ទី១ – បញ្ជីសម្បទានដីនៅក្នុងតំបន់ការពារធម្មជាតិ)។

៤. ក្នុងដំណើរបេសកម្មនៅក្នុងខែឧសភា ឆ្នាំ២០១២ ខ្ញុំបានធ្វើទស្សនកិច្ចទៅកាន់ខេត្តរតនគីរី ស្ទឹងត្រែង និងខេត្តក្រចេះ ក៏ដូចជានៅរាជធានីភ្នំពេញ។ នៅក្នុងខេត្តនីមួយៗខ្ញុំបានជួបជាមួយសហគមន៍មួយចំនួនដែលរងផលប៉ះពាល់ពីសម្បទានដី ក៏ដូចជាជាមួយអាជ្ញាធរខេត្ត។ ខ្ញុំបានព្យាយាមទាក់ទងជាមួយក្រុមហ៊ុនផ្សេងៗដែលត្រូវបានរដ្ឋាភិបាលផ្តល់សម្បទានពាក់ព័ន្ធអោយ ហើយខ្ញុំនឹងខិតខំប្រឹងប្រែងតទៅទៀត ដើម្បីប្រាស្រ័យទាក់ទងជាមួយក្រុមហ៊ុនទាំងនេះ ដែលពួកគេជាតួអង្គគន្លឹះក្នុងការប្រតិបត្តិការសម្បទានដី និងជាតួអង្គសំខាន់ដែលទទួលផលពីសម្បទានទាំងនោះ។ ខ្ញុំក៏បានជួបផងដែរជាមួយតំណាងសង្គមស៊ីវិលជាច្រើន ជួបជាមួយក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដី នគរូបនីយ កម្មនិងសំណង់ តំណាងទូត និងអ្នកផ្តល់ជំនួយ និងក្រុមអង្គការសហប្រជាជាតិប្រចាំកម្ពុជា។ ខ្ញុំមានការសោកស្តាយ ដែលខ្ញុំមិនបានជួបជាមួយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ជាពិសេសពីព្រោះតែក្រសួងនេះ គឺជាអង្គភាពមួយរបស់រដ្ឋាភិបាលដែលពាក់ព័ន្ធខ្លាំងជាងគេក្នុងវិស័យសម្បទានដីនេះ។ ព័ត៌មានបន្ថែមមួយចំនួន ត្រូវបានផ្តល់ អោយដោយក្រសួងបរិស្ថាន និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។

៥. អំឡុងបេសកកម្មថ្មីៗបំផុតរបស់ខ្ញុំ កាលពីថ្ងៃទី ៧ ឧសភា ឆ្នាំ២០១២ លោកនាយករដ្ឋមន្ត្រីបានប្រកាសពីកិច្ចផ្តួចផ្តើមរបស់រដ្ឋាភិបាលទាក់ទងនឹងសម្បទានដីសេដ្ឋកិច្ច រួមមានទាំង ការគ្រប់គ្រងលើការផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី និងការត្រួតពិនិត្យឡើងវិញលើការអនុវត្តន៍ ទាក់ទងនឹងកិច្ចសន្យានិងកាតព្វកិច្ចតាមច្បាប់របស់សម្បទានិក នៃសម្បទានដីដែលមានស្រាប់ ។ ជាបន្តបន្ទាប់ លោកនាយករដ្ឋមន្ត្រីបានប្រកាសអំពីកិច្ចផ្តួចផ្តើមធ្វើប័ណ្ណកម្មសិទ្ធិដីសម្រាប់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់សម្បទាន។ របាយការណ៍នេះក៏ពិចារណាផងដែរពីការវិវឌ្ឍន៍ថ្មីៗទាំងអស់នេះ និងស្វះស្វែងដើម្បីបង្កើតឲ្យមានទិដ្ឋភាពវិជ្ជមានមួយចេញពីកិច្ចផ្តួចផ្តើមទាំងនះ។ របាយការនេះធ្វើការវិភាគរាល់ព័ត៌មានដែលខ្ញុំបានទទួលតាំងពីដើមដំបូងនៃអាណត្តិរបស់ខ្ញុំ ក្នុងឆ្នាំ ២០០៩ រហូតមកទល់ចុងខែកក្កដា ឆ្នាំ២០១២ រាប់ទាំងក្របខ័ណ្ឌច្បាប់ជាតិគ្រប់គ្រងលើសិទ្ធិដីធ្លី (ច្បាប់ និងគោលនយោបាយផ្សេងៗពាក់ព័ន្ធនឹងតំបន់ការពារធម្មជាតិ) ការវិវឌ្ឍន៍ជាអន្តរជាតិទាក់ទងនឹងកាតព្វកិច្ចសិទ្ធិមនុស្សរបស់កម្ពុជាលើវិស័យដីធ្លី និងផលប៉ះពាល់នៃសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃផ្សេងទៀតទៅលើការទទួលបានសិទ្ធិមនុស្ស។ ករណីមួយចំនួនដែលបានជ្រើសសម្រាំងនៅក្នុងរបាយការណ៍នេះឆ្លុះបញ្ចាំងពីការបង្ហាញជូនទាំងនេះ។ របាយការណ៍នេះផ្អែកលើទិន្ន័យ និងព័ត៌មានផ្លូវការរបស់រដ្ឋាភិបាល ញត្តិជាបុគ្គល និងសក្ខីកម្មដែលបានដាក់តាមរយៈបុគ្គល សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ។ របាយការណ៍នេះក៏បានមកពីការសិក្សាស្រាវជ្រាវដែលបានធ្វើឡើង ដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR) នៅកម្ពុជា ដែលបាននិងកំពុងបន្តតាមឃ្លាំមើល និងធ្វើការតស៊ូមតិលើបញ្ហានេះ។ ខ្ញុំសូមថ្លែងអំណរគុណដល់ការិយាល័យOHCHR នៅកម្ពុជា ចំពោះការជួយឧបត្ថម្ភគាំទ្រដ៏មានតំលៃក្នុងបញ្ហានេះ។ ទន្ទឹមនឹងគ្រប់សកម្មភាពការងារទាំងអស់របស់ខ្ញុំមានការសហការពីរដ្ឋាភិបាលក្តី ក៏ជាការគួរកត់សំគាល់ផងដែរថា ឯកសារ

ផ្លូវការដែលត្រូវការចាំបាច់សំរាប់ធ្វើការវិភាគឲ្យបានពេញលេញទាំងស្រុង មិនមានគ្រប់គ្រាន់ទេ ហើយព័ត៌មានទៀតសោធក៏នៅមានភាពចន្លោះប្រហោងដែរ។

## IX. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១៩៦. ជាបឋម គេគួរកត់សំគាល់ថា កាលៈទេសៈប្រវត្តិសាស្ត្រ រួមមានគោលនយោបាយនៃរបបខ្មែរក្រហម ព្រមទាំងវិនាសកម្ម និងការផ្លាស់ទីលំនៅទូទាំងប្រទេស ដែលបានបន្សល់ទុកពីសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃនៅប្រទេសកម្ពុជា បាននាំឲ្យកើនឡើងទំនាស់ដីធ្លីដ៏រាលដាល ដែលរដ្ឋាភិបាលកំពុងតែព្យាយាមគ្រប់គ្រង។ លើសពីនេះទៀត គេក៏គួរកត់សំគាល់ផងដែរថា ក្នុងនាមជាប្រទេសកំពុងអភិវឌ្ឍន៍ ប្រទេសកម្ពុជាប្រាថ្នាយកការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិរបស់ខ្លួនធ្វើជាអាទិភាពដើម្បីអភិវឌ្ឍប្រទេសឲ្យបានកាន់តែរុងរឿង។ ទោះបីជាដូច្នោះក៏ដោយ ខ្ញុំយល់ឃើញថា សម្បទានដីគួរត្រូវបានផ្តល់ និងគ្រប់គ្រងនៅក្នុងក្របខ័ណ្ឌច្បាប់ និងគោលនយោបាយដ៏សមប្រកបមួយ រួមមានការគិតគូដល់ និងពិគ្រោះយោបល់ជាមួយ អ្នកដែលនឹងរងការប៉ះពាល់ និងគិតគូដល់ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចិរភាពផង។

១៩៧. ភាគច្រើននៃការប្រឈម ដែលខ្ញុំបានរកឃើញនៅក្នុងរបាយការណ៍នេះ (បានវិភាគនៅក្នុងផ្នែកទី V ដល់ VIII) កើតចេញមកពីការខកខានមិនអនុវត្តក្របខ័ណ្ឌគតិយុត្តក្នុងស្រុក មានជាអាទិ៍ ច្បាប់ គោលនយោបាយ និងបទបញ្ញានានា ដែលរដ្ឋាភិបាលខ្លួនឯងបានបង្កើត (បានពន្យល់នៅក្នុងផ្នែកទី III)។ ការផ្តល់ និងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងៗទៀតនៅកម្ពុជា ខ្វះខាតយ៉ាងខ្លាំងនូវតម្លាភាព និងការគោរពច្បាប់ដែលមានស្រាប់ ។ ភាគច្រើននៃក្របខ័ណ្ឌគតិយុត្តលើវិស័យនេះមានការតាក់តែងឡើងបានយ៉ាងល្អប្រសើរនៅលើក្រដាស ប៉ុន្តែបញ្ហាចោទគឺនៅលើការអនុវត្តជាក់ស្តែង។

១៩៨. លើសពីនេះទៀត បញ្ហាដ៏ធ្ងន់ធ្ងរដែលខ្ញុំបានជួបប្រទះ គឺភាពមិនប្រក្រតីនៃការទទួលបានព័ត៌មាន ដែលបានរួមចំណែកធ្វើឲ្យសម្បទាននានាផ្តល់ផលប្រយោជន៍ដល់តែក្រុមមនុស្សភាគតិចប៉ុណ្ណោះ និងកំណើននៃទំនាស់ដែលទាក់ទងនឹងដីធ្លី ដែលមានសក្តានុពលរួមចំណែកដល់អស្ថេរភាពជាតិ។ រដ្ឋាភិបាលគួរតែមានភាពម៉ឺងម៉ាត់ និងមានតម្លាភាព ក្នុងការផ្តល់ និងគ្រប់គ្រងសម្បទានដី (ផ្នែកទី II និង VI) ជាពិសេស នៅពេលចរចាកិច្ចព្រមព្រៀងសម្បទាន ជាមួយក្រុមហ៊ុនបរទេស និងក្នុងស្រុកនានាដោយបញ្ចៀសឲ្យបាននូវទំនាស់ខាងផលប្រយោជន៍ ព្រមទាំងដាក់ក្រុមហ៊ុន ដែលទទួលបានសម្បទានឲ្យមានគណនេយ្យភាព ដោយអនុវត្តការត្រួតពិនិត្យលើសកម្មភាពនានា របស់ពួកគេ និងដោះស្រាយចំពោះទំនាស់ដីធ្លី។ ការខ្វះតម្លាភាពនៅក្នុងបញ្ហាទាំងនេះ បង្កឲ្យមានការសង្ស័យអំពីអំពើពុករលួយនៅគ្រប់កំរិតទាំងអស់នៃរដ្ឋាភិបាល និងធ្វើឲ្យប្រជាពលរដ្ឋកម្ពុជាជាច្រើនមានការថ្នាំងថ្នាក់។ ទោះបីជាខ្ញុំបានធ្វើទស្សនៈកិច្ចនៅកម្ពុជាតាំងពីឆ្នាំ២០០៩ និងទទួលបានកិច្ចសហប្រតិបត្តិការ ល្អប្រសើរពីរដ្ឋាភិបាលនៅក្នុងវិស័យជាច្រើនក្នុងរង្វង់អាណត្តិរបស់ខ្ញុំក្តី ក៏ខ្ញុំនៅមានការលំបាកក្នុងការទទួលបានព័ត៌មានផ្លូវការចាំបាច់នានា ក៏ដូចជាក្នុងការចូលទៅជួប ក្រុមហ៊ុននានា ដែលទទួលបានសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងៗទៀត។ កង្វះការទទួលបានព័ត៌មានសំខាន់ៗទាំងនេះ ធ្វើឲ្យមានការលំបាកជាខ្លាំងដើម្បីសរសេររបាយការណ៍ដ៏គ្រប់ជ្រុងជ្រោយមួយស្តីពីបញ្ហាទាំងអស់នេះ។

១៩៩. ជាទីផ្សារដែលកំពុងងើបឡើង ប្រទេសកម្ពុជាមានហានិភ័យក្នុងការកសាងកេរ្តិ៍ឈ្មោះលើឆាកអន្តរជាតិ ចំពោះសុវត្ថិភាពនៃការធ្វើវិនិយោគនៅក្នុងវិស័យដីធ្លី និងវិស័យទូទៅផ្សេងទៀត។ បរិយាកាសនៃការអភិវឌ្ឍបច្ចុប្បន្ន ត្រូវបានកំណត់ចរិតលក្ខណៈដោយតម្លាភាពដែលមានកំរិតទាប និងការទទួលបានព័ត៌មានមិនសមាមាត្រគ្នា ការពិគ្រោះយោបល់មិនគ្រប់គ្រាន់ និងការចូលរួមដែលមិនមាន ភាពពេញលេញហើយតាមការយល់ឃើញរបស់ខ្ញុំ នេះគឺជាការពុំមានចិរភាព និងទំនងជាធ្វើឲ្យរាំងស្ទះដល់ការរីកចំរើននៃសេដ្ឋកិច្ចជាតិនាពេលអនាគត។ ពិតណាស់ថា មានករណីសម្បទានដីខ្លះ ហាក់ដូចជាមាន

ផលប៉ះពាល់វិជ្ជមានសម្រាប់ប្រជាជនកម្ពុជា ទាក់ទិននឹងការបង្កើតការងារធ្វើ បង្កើនសេដ្ឋកិច្ចពលរដ្ឋមូលដ្ឋាន ផ្តល់ចំណូលសម្រាប់ជួយផ្នែកហិរញ្ញវត្ថុដល់សេវាសាធារណៈ និងលើកកំពស់ដល់ការអភិវឌ្ឍជាតិទាំងមូល។ ទោះជាដូច្នោះក៏ដោយ តម្លៃនៃការខូចខាតចំពោះមនុស្សដោយសម្បទានដីជាច្រើនមានកំរិតខ្ពស់ ហើយសិទ្ធិមនុស្សគួរតែជាកត្តាស្នូលដែលត្រូវយកចិត្តទុកដាក់ខ្ពស់នៅចំពោះមុខនៃការផ្តល់ និងការគ្រប់គ្រងនៃសម្បទានដីនានា ដើម្បីធ្វើឲ្យសម្បទានទាំងនោះមានផលប៉ះពាល់វិជ្ជមាន។ មានការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ និងធំធេង ដែលត្រូវបានកត់ត្រាទុកយ៉ាងច្បាស់លាស់ ពាក់ព័ន្ធនឹងសម្បទានដីដែលត្រូវការលើកយកមកដោះស្រាយ និងកែតម្រូវវិញ។ ការចោទប្រកាន់សកម្មជនដីធ្លី និងអ្នកការពារសិទ្ធិមនុស្សពីបទព្រហ្មទណ្ឌ គឺជាបញ្ហាកង្វល់ដ៏ធ្ងន់ធ្ងរ ខណៈដែលសេរីភាពខាងការបញ្ចេញមតិ និងខាងការប្រមូលផ្តុំ ជាកត្តាតម្រូវចាំបាច់សម្រាប់សង្គមដែលប្រកាន់លទ្ធិប្រជាធិបតេយ្យពិតប្រាកដ។

២០០. លើសពីនេះទៀត ក្នុងការវិភាគរបស់ខ្ញុំ ខ្ញុំបានមានការលំបាកក្នុងការយល់ច្បាស់ទាំងស្រុងនូវអត្ថប្រយោជន៍នៃសម្បទានដីជាច្រើន ដែលរដ្ឋាភិបាលបានផ្តល់។ ជាទូទៅ វាមិនច្បាស់លាស់ទេថាតើទំហំនៃអត្ថប្រយោជន៍ដែលប្រជាជនកម្ពុជាទទួលបានពីសម្បទានដីមានយ៉ាងណា។ ខ្ញុំមានក្តីបារម្ភថា ថ្វីបើរដ្ឋាភិបាលកម្ពុជាមានឆន្ទៈក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយក៏ដោយ ក៏មានសម្បទានិកជាច្រើនបាននឹងកំពុងធ្វើប្រតិបត្តិការរបស់ខ្លួនដោយលាក់កំបាំង។ ចំណូលពីសម្បទានដីដែលមានស្រាប់ ដែលរកបាន ត្រូវគន់គូរពីកំរិតចំណូលទាំងអស់ និងធ្វើឲ្យកាន់តែច្បាស់លាស់ឡើង។ ប្រសិនបើផលប្រយោជន៍ដូចជាចំណូលបែបនេះ មិនបានស្តែងចេញអោយឃើញទេ នោះ គោលនយោបាយ និងការអនុវត្តនានាជុំវិញការផ្តល់សម្បទានដី ត្រូវការកែតម្រូវ។ ផលប៉ះពាល់នានានៃសម្បទានដីគួរតែត្រូវបានវិភាគទាំងសម្រាប់កម្មវិបាករយៈពេលខ្លីនិងរយៈពេលវែង។ ប្រាកដណាស់ថា ផលចំណូលគួរតែជាក់ស្តែង និងផ្តល់អត្ថប្រយោជន៍ដល់មនុស្សភាគច្រើន ដើម្បីអាចចាត់ទុកថា មានសារៈប្រយោជន៍។ ខ្ញុំយល់ឃើញថា ការអភិវឌ្ឍវិស័យដីធ្លី និងធនធានធម្មជាតិរបស់ប្រទេសកម្ពុជា អាចនឹងមានផលប៉ះពាល់វិជ្ជមានលើជីវិតរបស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ ប្រសិនបើវាត្រូវបានអនុវត្តនៅក្នុងលក្ខណៈដែលមានចេរភាពនិងសមធម៌ និងនៅក្នុងក្របខ័ណ្ឌនៃកាតព្វកិច្ចខាងសិទ្ធិមនុស្សរបស់រដ្ឋាភិបាលកម្ពុជា។ នៅក្នុងស្មារតីស្ថាបនានេះដែលខ្ញុំសូមដាក់ជូននូវអនុសាសន៍ទាំងអស់នេះ។

## ក. ការទទួលបានព័ត៌មាន និងតម្លាភាព

២០១. រដ្ឋាភិបាលកម្ពុជាគួរតែបង្ហាញព័ត៌មានអំពីការវិនិយោគនានាលើដីធ្លី ប្រត្តិបត្តការដីធ្លី និងដំណើរការដេញថ្លៃ ការពិនិត្យលើសំណើរសុំសម្បទានដី (និងលក្ខណៈវិនិច្ឆ័យនៃការសំរេចចិត្ត ចំពោះការយល់ព្រម ឬបដិសេធសំណើរ) និងផែនការអនាគត (រួមមានការចាប់ផ្តើមដំណើរការសកម្មភាពសម្បទានដី) ដល់សាធារណជន រួមមាន តាមរយៈការបង្ហាញជាសាធារណៈនៅថ្នាក់ខេត្ត និងបង្ហោះព័ត៌មានទាំងអស់នោះលើគេហទំព័រផ្លូវការនានារបស់រដ្ឋាភិបាល។

២០២. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរតែធ្វើបច្ចុប្បន្នភាព និងបំពេញបញ្ជីសម្បទានដីសេដ្ឋកិច្ច និងសម្បទានព្រៃដែលមានស្រាប់របស់ខ្លួន នូវព័ត៌មានដ៏ពេញលេញ រួមមានការវិវត្តន៍រីកចម្រើននៃប្រតិបត្តិការសម្បទានដីទាំងនោះ និងបង្ហាញព័ត៌មាននោះជាសាធារណៈឲ្យបានទាន់ពេលវេលា។ បញ្ជីនោះគួររួមបញ្ចូល ពត៌មានអំពីក្រុមហ៊ុន ថ្នាក់ដឹកនាំ ម្ចាស់ភាគហ៊ុន ក្រុមហ៊ុនមេ និងព័ត៌មានទំនាក់ទំនងនៃការិយាល័យមូលដ្ឋានរបស់ក្រុមហ៊ុន (រួមទាំង ការិយាល័យនានានៅក្នុងប្រទេសសាម៉ីបើមាន) ថ្លៃឈ្នួលដី

សម្បទានដែលបានបង់ និងចំណូលនានាដែលបានមកពីសម្បទានដីទាំងអស់នោះ។ ព័ត៌មាននេះគួរតែមានជាភាសាអង់គ្លេស និងភាសាខ្មែរ។

២០៣. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គួរផ្សព្វផ្សាយព័ត៌មានស្តីពី ការកំណត់លើផែនទី ការធ្វើចំណាត់ថ្នាក់ និងការចុះបញ្ជី ដីសាធារណៈ និងដីឯកជនរបស់រដ្ឋ ព្រមទាំងបង្កើត និងរក្សាប្រព័ន្ធទិន្នន័យដីធ្លីរដ្ឋ។ ព័ត៌មានស្តីពីការលៃបម្រុង ការគ្រប់គ្រង និងការធ្វើអនុបយោគដីរដ្ឋ គួរតែផ្សព្វផ្សាយជាសាធារណៈ ស្របតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋឆ្នាំ ២០០៥ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរតែធ្វើសហប្រតិបត្តិការនៅក្នុងដំណើរការនេះ និងចែករំលែកព័ត៌មានទាក់ទងនឹងការធ្វើអនុបយោគទ្រព្យសម្បត្តិរបស់រដ្ឋ។

២០៤. ក្រសួងបរិស្ថានគួរតែបង្ហាញឲ្យសាធារណជនបានដឹងពីបញ្ជីឈ្មោះបច្ចុប្បន្ន និងដែលបានធ្វើបច្ចុប្បន្នភាពនៃគ្រប់តំបន់ការពារទាំងអស់ រួមមានឧទ្យានជាតិ ដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង តំបន់រ៉ាមសារ តំបន់ស្នូលនៃបរិមណ្ឌលជីវមណ្ឌល តំបន់បេតិកភ័ណ្ឌធម្មជាតិ និងតំបន់ឧទ្យានជាតិសមុទ្រ ដែលរួមមានព័ត៌មានពិស្តារអំពីទំហំ ព្រំប្រទល់ តំបន់គ្រប់គ្រង និងការប្រើប្រាស់នៃតំបន់ទាំងនោះ ព្រមទាំងអំពីដំណើរការនៃការធ្វើសេចក្តីសំរេចចិត្តចំពោះការកែប្រែ ឬការធ្វើអនុបយោគនូវតំបន់ការពារនានា។

២០៥. ដំណើរការនៃការធ្វើអនុបយោគដីរដ្ឋទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងការចាត់ថ្នាក់តំបន់គ្រប់គ្រងក្នុងតំបន់ការពារនានា ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព គួរត្រូវបានធ្វើនៅក្នុងបរិយាកាសមួយប្រកបដោយតម្លាភាព និងបើកចំហ ដោយមានតួអង្គពាក់ព័ន្ធទាំងអស់ រួមមានក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ខ. ការផ្តល់សម្បទានដី - ការពិគ្រោះយោបល់ និងការត្រួតពិនិត្យ

២០៦. ប្រព័ន្ធដែលកាន់តែមានការសម្របសម្រួល និងការចូលរួមពីអ្នកពាក់ព័ន្ធ ក្នុងការផ្តល់សម្បទានដីនានា គួរតែត្រូវបានយកទៅពិចារណាដោយរដ្ឋាភិបាល និងអនុវត្តដោយអាជ្ញាធរពាក់ព័ន្ធ រួមមានការពិចារណាលើដំណើរការធ្វើផែនការនៅថ្នាក់ជាតិ និងខេត្ត។ វិធីសាស្ត្រនេះគួរតែបើកឲ្យមាន ការចូលរួម និងដំណើរការអភិវឌ្ឍន៍ប្រកបដោយការចូលរួម ដោយអនុលោមតាមផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិបច្ចុប្បន្នភាព (២០០៩ - ២០១៣)។

២០៧. ស្ថាប័នរដ្ឋាភិបាល និងសហគ្រាសពាណិជ្ជកម្មដែលពាក់ព័ន្ធទាំងអស់ គួរតែប្រកាន់តាមលក្ខខណ្ឌដែលច្បាប់តម្រូវ សម្រាប់ការពិគ្រោះយោបល់ជាសាធារណៈ ឧទាហរណ៍ អនុក្រឹត្យឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច។ ការពិគ្រោះយោបល់បែបនោះគួរតែប្រកបដោយអត្ថន័យ មានការចូលរួមពីអ្នកពាក់ព័ន្ធ និងបើកចំហដល់អ្នករងការប៉ះពាល់នានា។ សហគមន៍នានាដែលស្ថិតនៅលើដីដែលនឹងរងការប៉ះពាល់ដោយការផ្តល់សម្បទានដី គួរតែត្រូវបានពិគ្រោះយោបល់នៅដំណាក់កាលដំបូងបំផុតនៃផែនការប្រើប្រាស់ដី និងគួរត្រូវបានរួមបញ្ចូល នៅក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្ត។ គួរមានការពិចារណាយ៉ាងហ្មត់ចត់ដល់សកម្មភាពចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់សហគមន៍នោះ និងគិតគូរអំពីកិច្ចខិតខំប្រឹងប្រែងទាំងអស់ដែលត្រូវធ្វើឡើងដើម្បីបញ្ចៀសឲ្យបានការរំខានដល់ពួកគាត់។ ស្តង់ដារនៃការយល់ព្រមដោយសេរី ជាមុន និងមានការជូនដំណឹងគ្រប់គ្រាន់ គួរតែត្រូវបានអនុវត្ត យ៉ាងម៉ឺងម៉ាត់ នៅពេលពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិចទាំងអស់។

២០៨. ការពិនិត្យពិច័យកាន់តែហ្មត់ចត់ឡើងលើប្រវត្តិ និងសាវតារបស់សហគ្រាសពាណិជ្ជកម្ម និងសមត្ថភាពធ្វើប្រតិបត្តិការនៃសំណើរវិនិយោគរបស់ពួកគេ គួរតែត្រូវបានធ្វើឡើងដោយអាជ្ញាធរពាក់ព័ន្ធនានា ដើម្បីត្រួតពិនិត្យមើលវិនិយោគិននានាមុនពេលផ្តល់សម្បទានដីណាមួយ។ ការពិនិត្យលើសំណើរវិនិយោគ គួរតែត្រូវបានប្រព្រឹត្តទៅក្នុងលក្ខណៈតម្លាភាពមួយ ដោយថ្លឹងថ្លែងរវាង ការចង់រក្សាការសម្ងាត់នៃព័ត៌មានរសើបរបស់ក្រុមហ៊ុន និងតំរូវការសម្រាប់ការពិនិត្យជាសាធារណៈ។ កិច្ចការនេះរួមមានការផ្សព្វផ្សាយព័ត៌មាន ស្តីពីដំណើរការដេញថ្លៃជាសាធារណៈ និងបន្ទាត់ពេលវេលា អំពីសកម្មភាពសម្បទាននានាដែលបានព្រមព្រៀង។

២០៩. ការធ្វើអនុបយោគដីសាធារណៈរបស់រដ្ឋទៅជាដីឯកជនរបស់រដ្ឋ គួរធ្វើតាមនីតិវិធី ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងក្រោមច្បាប់ភូមិបាលឆ្នាំ២០០១ និងនីតិវិធីដែលតំរូវឲ្យមានការអនុម័តច្បាប់ដោយរដ្ឋសភា។ រហូតដល់ច្បាប់បែបនោះត្រូវបានអនុម័ត អនុបយោគណាមួយដែលបានកំណត់ គួរតែត្រូវបានធ្វើឡើងក្នុងលក្ខណៈបើកចំហ និងតម្លាភាពមួយ ដោយពិចារណាយ៉ាងល្អិតល្អន់អំពីផលប៉ះពាល់ជាសក្តានុភូតនានានៃការធ្វើអនុបយោគតំបន់ជាក់លាក់ណាមួយ ព្រមទាំងមាន ការពិគ្រោះយោបល់ត្រឹមត្រូវជាមួយទីភ្នាក់ងារបច្ចេកទេសដែលពាក់ព័ន្ធនានា និងប្រជាពលរដ្ឋដែលរងការប៉ះពាល់។

២១០. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត គួរតែធានាថាដំណើរការដេញថ្លៃប្រកបដោយការប្រកួតប្រជែងមួយ សម្រាប់ការផ្តល់សម្បទានដី ត្រូវបានអនុវត្តកាន់តែម៉ឺងម៉ាត់ និងតម្លាភាព ឧទាហរណ៍ តាមអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ចឆ្នាំ២០០៥។

២១១. បទបញ្ជាទាក់ទងនឹងការផ្អាកសម្បទានដីសេដ្ឋកិច្ច (ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២) ដែលផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី គឺជាចំណាត់ការគួរជាទីស្វាគមន៍ ប៉ុន្តែគួរត្រូវបានអនុវត្តយ៉ាងពេញលេញ និងរក្សាសុពលភាពរហូតដល់ប្រព័ន្ធពិនិត្យការផ្តល់សម្បទានមួយត្រូវបានបង្កើតចប់សព្វគ្រប់។ សម្បទាននានាដែលត្រូវបានរកឃើញថា មានការគេងប្រវ័ញ្ច អសកម្ម ឬម្យ៉ាងវិញទៀតរំលោភលើលក្ខខណ្ឌនានានៃកិច្ចព្រមព្រៀងសម្បទានគួរត្រូវបានមោឃភាព យោងតាមច្បាប់ពាក់ព័ន្ធនានា។ ការពិនិត្យមើលលើសម្បទាននាពេលបច្ចុប្បន្នឡើងវិញ រួមទាំងការងាររបស់លេខាធិការដ្ឋានបច្ចេកទេសស្តីពីសម្បទានដីសេដ្ឋកិច្ច គួរតែត្រូវបានផ្សព្វផ្សាយជាសាធារណៈ ឲ្យបានទាន់ពេលវេលា។ បន្ទាប់ពីពិនិត្យរួចហើយ ព័ត៌មានលំអិតនៃសម្បទានទាំងឡាយដែលត្រូវបានមោឃភាព តាមរយៈដំណើរការនេះ ឬត្រូវបានមោឃភាពនាពេលកន្លងមក គួរតែត្រូវបានផ្សព្វផ្សាយជាសាធារណៈ រួមទាំងព័ត៌មានអំពីការគ្រប់គ្រងសម្បទានដីដែលត្រូវបានមោឃភាពផងដែរ។

## គ. ការផ្តល់សម្បទានដី - ការការពារបរិស្ថាន និងសង្គម

២១២. រដ្ឋាភិបាលគួរតែត្រូវបានធ្វើឲ្យប្រសើរឡើងនូវរាល់កិច្ចខិតខំប្រឹងប្រែងទាំងអស់ ដើម្បីអនុវត្តច្បាប់គោលនយោបាយ និងបទបញ្ញានានា ដែលតំរូវឲ្យធ្វើការវាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គម *មុនពេល*ផ្តល់សម្បទានដី រួមមាន ច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឆ្នាំ១៩៩៦ ហើយការរកឃើញបានមកពីការវាយតម្លៃទាំងនោះត្រូវផ្សព្វផ្សាយជាសាធារណៈ។

២១៣. វិធាន និងនីតិវិធីនានាទាក់ទងនឹងការធ្វើចំណាត់ថ្នាក់ និងការធ្វើអនុយោគដីក្នុងតំបន់ការពារនានា ជាពិសេសតំបន់ប្រើប្រាស់ដោយចីរភាព គួរតែត្រូវបានប្រកាន់ខ្ជាប់ (រួមមាន ដោយធ្វើការសិក្សាបែបវិទ្យាសាស្ត្រ ដូចមានចែងក្នុងច្បាប់ស្តីពីតំបន់ការពារឆ្នាំ២០០៨)។ លទ្ធផលនានា នៃការវាយតំលៃនោះ និងនីតិវិធីដែលទាក់ទងនឹងការចាត់ថ្នាក់ និងការធ្វើអនុប្រយោគ គួរត្រូវបានផ្សព្វផ្សាយជាសាធារណៈ។

២១៤. លក្ខខណ្ឌនានាដែលត្រូវបានកំណត់សំរាប់ការផ្ដល់សម្បទានដីនៅក្នុងតំបន់ការពារនានា យោងតាមច្បាប់ស្តីពីតំបន់ការពារឆ្នាំ២០០៨ គួរត្រូវបានប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់។ លើសពីនេះទៀត ការពិនិត្យឡើងវិញយ៉ាងហ្មត់ចត់នូវសម្បទានដី ដែលត្រូវបានផ្ដល់នៅក្នុងតំបន់ការពារនានាត្រូវតែធ្វើឡើងហើយ ការធ្វើមោឃភាពសម្បទានដីគួរត្រូវបានអនុវត្តឲ្យបានទាន់ពេលវេលា។ គួរធ្វើឲ្យសាធារណៈជនបានដឹងច្បាស់លាស់ផងដែរអំពីមូលដ្ឋានគតិយុត្តអ្វីខ្លះដែលមានសម្រាប់ស្ថាប័ននានា ក្រៅពី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការផ្ដល់សម្បទាន និងការធ្វើកិច្ចសន្យារយៈពេលវែងផ្សេងៗទៀត សម្រាប់ការអភិវឌ្ឍលើដីរដ្ឋ។

២១៥. ដីដែលត្រូវបានកាន់កាប់ និងប្រើប្រាស់ជាប្រពៃណីដោយប្រជាជនជនជាតិដើមភាគតិច គួរត្រូវបានកំណត់ និងវាស់វែងឲ្យបានឆាប់រហ័សបំផុត។ ពុំមានសម្បទានដីណាគួរត្រូវបានផ្ដល់លើ ឬក្បែរដីរបស់ប្រជាជនជនជាតិដើមភាគតិចនោះទេ *រហូតដល់*ដំណើរការទទួលស្គាល់ និងចុះបញ្ជីកម្មសិទ្ធិដីសមូហភាពបានចប់សព្វគ្រប់។ សារាចរអន្តរក្រសួងឆ្នាំ២០១១ ស្ដីពីវិធានការការពារជាបណ្ដោះអាសន្ន គួរត្រូវបានអនុវត្តយ៉ាងម៉ឺងម៉ាត់ សម្រាប់សហគមន៍ទាំងឡាយដែលត្រូវបានទទួលស្គាល់ដោយក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងមហាផ្ទៃ ហើយដំណើរការចុះកម្មសិទ្ធិដីសមូហភាពនេះ គួរធ្វើឲ្យបានរួសរាន់ដើម្បីបញ្ចៀសវិវាទនាពេលខាងមុខ។

២១៦. គួរតែពិចារណាលើសំណើរវិនិយោគរបស់សម្បទានិកណា ដែលមានទៅដោយ លក្ខខណ្ឌតំរូវតាមច្បាប់ និងបញ្ញត្តិច្បាប់រឹងមាំ ភ្ជាប់ជាមួយគម្រោងវិនិយោគរបស់ពួកគេ (ដូចជា គ្រោងការណ៍មានការទទួលស្គាល់ដោយភាគីទីបី និងក្រមប្រតិបត្តិដ៏ម៉ឺងម៉ាត់) ដែលរួមបញ្ចូល ស្តង់ដារអន្តរជាតិស្ដីពីចីរភាពបរិស្ថាន និងសង្គម។

## ឃ. សកម្មភាពសម្បទានដី

២១៧. ក្រុមហ៊ុនគ្រប់ទំហំ រចនាសម្ព័ន្ធ និងប្រភេទប្រតិបត្តិការទាំងអស់ ទាំងក្នុងស្រុក និងបរទេស និងទោះជាគ្រប់គ្រងទាំងស្រុង ឬមួយផ្នែកដោយរដ្ឋ គួរតែដោះស្រាយការប៉ះពាល់សិទ្ធិមនុស្សរបស់ពួកគេ ដោយអនុវត្តការយកចិត្តទុកដាក់ដ៏ត្រឹមត្រូវ រួមមានការអនុវត្តវិធានការកំណត់ បង្ការនិងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្ស និងមានគណនេយ្យភាពចំពោះសកម្មភាពពាណិជ្ជកម្មរបស់ពួកគេ។

២១៨. នៅក្នុងករណីនៃក្រុមហ៊ុនបរទេស រដ្ឋសាមីគួរតែធានាថា តំណាងនានា នៃសហគ្រាសពាណិជ្ជកម្មឯកជន ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន នឹងពុំរួមចំណែកធ្វើឲ្យមានការប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្សឡើយ ដោយធ្វើការឃ្លាំមើល និងត្រួតពិនិត្យជាទៀងទាត់។

២១៩. ការបណ្ដេញចេញ និងការផ្លាស់ប្ដូរទីលំនៅគួរតែត្រូវបានប្រើប្រាស់ជាដំណោះស្រាយចុងក្រោយប៉ុណ្ណោះ ហើយគួរតែត្រូវអនុវត្តការផ្អាកការបណ្ដេញចេញដោយបង្ខំដែលទាក់ទងនឹងសកម្មភាពសម្បទាននានា ។ នៅក្នុងករណីនៃការរំលោភកន្លងមក កិច្ចខិតខំប្រឹងប្រែងនានាគួរត្រូវបានធ្វើដើម្បីធានាដល់ការកែតម្រូវហេតុការណ៍អាក្រក់។ នៅពេលដែលនីតិវិធីត្រឹមត្រូវត្រូវបានគោរព ហើយការបណ្ដេញចេញត្រូវបានចាត់ទុកថាស្របច្បាប់ និងបម្រើផលប្រយោជន៍សាធារណៈ គ្រួសារដែលរងប៉ះពាល់នានា គួរត្រូវបានពិគ្រោះយោបល់អំពីរបៀប និងពេលវេលាដែលត្រូវធ្វើការផ្លាស់ប្ដូរលំនៅថ្មី ព្រមទាំងកិច្ចខិតខំប្រឹងប្រែងទាំងឡាយដែលត្រូវធ្វើដើម្បីធានាថា ការផ្លាស់ប្ដូរលំនៅថ្មីនោះនឹងប្រព្រឹត្តទៅក្រោមលក្ខខណ្ឌនានាដែលប្រកាន់ខ្ជាប់តាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ ទាក់ទងនឹងលំនៅដ្ឋានសមរម្យ និង

សំណងដែលត្រឹមត្រូវនិងយុត្តិធម៌។ កិច្ចខិតខំប្រឹងប្រែងជាបន្ថែមនានាគួរត្រូវបានធ្វើដើម្បីបង្កើតឡើងវិញនូវកាលានុវត្តភាពនៃការចិញ្ចឹមជីវិត។

២២០. កងយោធពលខេមរភូមិន្ទពុំគួរត្រូវបានប្រើប្រាស់ដើម្បីការពារផលប្រយោជន៍ឯកជន និងពុំគួរត្រូវបានដាក់ពង្រាយ ឬជួលដោយក្រុមហ៊ុនសម្បទានដីនានានោះទេ ទោះបីជាមានការឯកភាព ឬមិនឯកភាពពីរដ្ឋាភិបាលក៏ដោយ។ កងនគរបាល កងរាជអាវុធហត្ថ និងអាជ្ញាធរពាក់ព័ន្ធផ្សេងៗទៀតគួរអត់ធ្មត់ មិនប្រើប្រាស់កំលាំងលើសលប់ប្រឆាំងនឹងសហគមន៍ និងអ្នកតវ៉ានានាដែលរងការប៉ះពាល់ដោយសម្បទានដី។

២២១. រដ្ឋាភិបាលគួរធានាថា ក្រុមហ៊ុនសម្បទានដីនានាពុំប្រើប្រាស់ ឬលើកទឹកចិត្តឲ្យភ្នាក់ងារសន្តិសុខឯកជនចូលប្រឡូក ឬប្រើប្រាស់កំលាំងប្រឆាំងនឹងសហគមន៍ និងអ្នកតវ៉ាដែលរងការប៉ះពាល់ដោយសម្បទាននោះឡើយ។

២២២. ក្រុមហ៊ុនសម្បទានដីនានាគួរចាត់វិធានការទាំងអស់ដើម្បីបញ្ចៀសការបំផ្លិចបំផ្លាញបរិស្ថាន នៅក្នុងប្រតិបត្តិការរបស់ពួកគេ រួមមានការបង្ការការបំពុលទឹក ការធ្វើឲ្យខូចគុណភាពដី និងការឆ្ការដីដោយមិនចាំបាច់ ឬការកាប់ឈើដោយខុសច្បាប់។ ពួកគេគួរធានាថា ហេដ្ឋារចនាសម្ព័ន្ធ ដូចជាផ្លូវថ្មីៗនៅលើសម្បទានរបស់ពួកគេ អាចប្រើប្រាស់បានដោយសហគមន៍នៅជុំវិញនោះទាំងអស់ និងគួរជៀសវាងការបិទផ្លូវចរាចរណ៍នៅក្នុងបរិវេណតំបន់សម្បទាននោះ។

២២៣. រាល់កិច្ចខិតខំប្រឹងប្រែងទាំងអស់គួរត្រូវបានធ្វើដោយអាជ្ញាធរនានាដែលច្បាប់ប្រគល់សិទ្ធិឲ្យផ្តល់សម្បទាន ដើម្បីបង្ការសកម្មភាពនានានៅលើតំបន់ដែលមានតំលៃខាងវប្បធម៌ និងខាងសាសនាក៏ដូចជាដោះស្រាយ (តាមរយៈការកែតម្រូវហេតុការណ៍អាក្រក់) ផលប៉ះពាល់អវិជ្ជមានដែលបានកើតឡើងរួចហើយ។ ក្រសួងរដ្ឋាភិបាលដែលពាក់ព័ន្ធ ដូចជាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាចធ្វើអន្តរគមន៍ដើម្បីកែតម្រូវផលប៉ះពាល់ទាំងនោះ។

២២៤. ក្រុមហ៊ុនសម្បទានដីនានា ជាមួយការប្រើប្រាស់ចំណូលពីសកម្មភាពសម្បទាន គួរបង្កើនការរួមចំណែកនានារបស់ពួកគេទៅដល់សហគមន៍មូលដ្ឋាននានា រួមមាន ការផ្តល់អត្ថប្រយោជន៍ខាងសង្គមកិច្ចដូចជាសេវាសុខភាព ឱកាសទទួលបានការអប់រំ និងវិធានការការពារបរិស្ថាន។

## ង. ការឃ្លាំមើល ស្រាវជ្រាវ និងវិភាគ

២២៥. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដៃគូពាក់ព័ន្ធផ្សេងៗទៀត គួរស្វះស្វែងប្រមូលទិន្នន័យ និងធ្វើការវិភាគលើចំណូលដែលបានមកពីសម្បទានដីនានា និងបែងចែងអត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋ ដែលមានដូចជា ការងារដែលបង្កើតដោយក្រុមហ៊ុនសម្បទានដីនានា និងការរួមចំណែកដល់ទីផ្សារមូលដ្ឋាន ដែលកើតចេញមកពីកំណើនចំណូលជាផ្នែកមួយនៃការសិក្សាលើបរិមាណផ្អែកលើភស្តុតាង ទៅក្នុងប្រព័ន្ធសម្បទាន ។ ទិន្នន័យនេះ ក៏គួរត្រូវបានផ្សព្វផ្សាយជាសាធារណៈផងដែរ ។

២២៦. កាលានុវត្តភាពក្នុងការចិញ្ចឹមជីវិត និងរកចំណូលរបស់គ្រួសារនានាដែលរងផលប៉ះពាល់ដោយសម្បទាននានា គួរតែត្រូវបានពិនិត្យ និងកំណត់ជាផ្នែកមួយនៃការសិក្សាលើបរិមាណ និងគុណភាព ដោយលើកសំណើរដោះស្រាយផលប៉ះពាល់ខាងហិរញ្ញវត្ថុអវិជ្ជមាននានានៅក្នុងកម្រិតគ្រួសារ និងសហគមន៍ ។

២២៧. អ្នកស្រាយជ្រាវនានា គួរពិនិត្យបន្ថែមលើការរៀបចំផែនការ និងការពិគ្រោះយោបល់មិនគ្រប់គ្រាន់ ដែលកំពុងរួមចំណែកធ្វើឲ្យមានវិវាទទាក់ទងនឹងសម្បទានដីនានា ក្នុងគោលដៅវាយតំលៃជាបរិមាណនៃ (ក្នុងន័យហិរញ្ញវត្ថុ) ការបាត់បង់ចំណូលនៅកម្រិតថ្នាក់ជាតិ ។

២២៨. ការឃ្លាំមើលកាន់តែហ្មត់ចត់លើការប្រើប្រាស់ដីធ្លី គួរត្រូវបានធ្វើ ហើយការមោឃភាពសម្បទានដី គួរត្រូវបានអនុវត្តឲ្យបានទាន់ពេលវេលា ហើយប្រសិនបើអាចធ្វើទៅរួច ប្រគល់ដីនោះឲ្យអ្នកប្រើប្រាស់ផ្សេងៗទៀត។ សម្បទានដីដែលត្រូវបានមោឃភាព គួរត្រូវបានចុះបញ្ជីដោយក្រុមហ៊ុន ឬ អាជ្ញាធរខេត្ត និងផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័ររបស់ក្រសួងពាក់ព័ន្ធនានា ដោយភ្ជាប់ជាមួយមូលហេតុនៃមោឃភាព ។

២២៩. ក្នុងករណីដែលសម្បទានដីត្រូវបានផ្តល់លើដីដែលកាន់កាប់ និងប្រើប្រាស់ជាប្រពៃណីដោយជនជាតិដើមភាគតិច ដីនោះគួរត្រូវប្រគល់ និងស្តារស្ថានភាពសម្រាប់ឲ្យពួកគេឡើងវិញ រួមទាំងផ្តល់កាលានុវត្តភាពដល់សហគមន៍ទាំងនោះ ក្នុងការចុះបញ្ជីជានីតិបុគ្គល និងដាក់ពាក្យសុំចុះបញ្ជីដីកម្មសិទ្ធិសមូហភាពផងដែរ ។

២៣០. បន្ទាប់ពីសម្បទាននានាត្រូវបានផ្តល់ និងដាក់ឲ្យដំណើរការរួចហើយ ការឃ្លាំមើលគួរបន្តធ្វើ និងវាយតំលៃលើការប៉ះពាល់បរិស្ថាន ការអនុវត្តច្បាប់ការងារ និងការប្រព្រឹត្តជាទូទៅរបស់សម្បទានិកជាទៀងទាត់ ដើម្បីធានាថាការអនុវត្តន៍មិនពេញលេញអាចត្រូវបានដោះស្រាយ ឬដាក់ទណ្ឌកម្ម ។

២៣១. រដ្ឋាភិបាល គួរពិនិត្យឡើងវិញលើការរំលោភលក្ខខណ្ឌកំណត់ដែលកម្រិតទំហំដីសម្បទានមិនលើសពី ១០.០០០ ហិកតា សម្រាប់បុគ្គលតែមួយ និង ការអនុវត្តន៍នៃការផ្តល់ក្បាលដីជាប់គ្នា ដល់បុត្រសម្ព័ន្ធភាព ឬសមាជិកគ្រួសាររបស់សម្បទានិក ។ រដ្ឋាភិបាល គួរអះអាងបញ្ជាក់ និងអនុវត្តការដាក់កំហិតគតិយុត្តដែលមានចែងក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ ថាសម្បទានដីដែលមានទំហំច្រើនជាង ១០.០០០ ហិកតា មិនអាចត្រូវបានផ្តល់ជូនបុគ្គលតែម្នាក់ ឬឲ្យនីតិបុគ្គលច្រើនដែលគ្រប់គ្រងដោយរូបវន្តបុគ្គល ឬនីតិបុគ្គលដដែលៗនោះទេ ។ ប្រសិនជាអាចអនុវត្តទៅរួច សម្បទានដីដែលល្មើសនឹងបទប្បញ្ញត្តិនេះ គួរតែត្រូវបានមោឃភាពចោល ។

## ច. ការដោះស្រាយទំនាស់

២៣២. អាស្រ័យដោយស្ថានការណ៍ដែលហាក់ដូចជាមិនស្រាកស្រាននៃទំនាស់ដីធ្លីដ៏រ៉ាំរ៉ៃ និងកំណើននៃទំនាស់ថ្មីៗ កិច្ចខិតខំប្រឹងប្រែងនានាគួរតែត្រូវបានធ្វើឡើង ដើម្បីបង្កើនប្រសិទ្ធិភាព និងធម្មានុរូបនៃយន្តការដោះស្រាយបណ្តឹងតវ៉ានៅកម្រិតប្រតិបត្តិការនានា ដោយផ្តល់ឲ្យសហគមន៍ និងតំណាងរបស់ពួកគេ (សហគមន៍អាចធ្វើការសម្រេចថាតើគួរឲ្យអង្គការសង្គមស៊ីវិលចូលពាក់ព័ន្ធឬយ៉ាងណា) ចូលរួមតាំងពីនៅតំណាក់កាលដំបូងបំផុតនៃការផ្តល់សម្បទានដីព្រមទាំងរួមបញ្ចូលពួកគេនៅក្នុងដំណើរការធ្វើផែនការផងដែរ ។

២៣៣. តំណាងក្រុមហ៊ុននានាគួរមានវត្តមាន និងចូលរួមយ៉ាងពេញលេញនៅក្នុងយន្តការដោះស្រាយវិវាទថ្នាក់មូលដ្ឋាននានា ដើម្បីបន្ធូរបន្ថយសតិអារម្មណ៍ប្រឆាំងក្រុមហ៊ុន និងលើកទឹកចិត្តដល់សហគមន៍វិនិយោគឲ្យលើកយកមកដោះស្រាយដោយផ្ទាល់នូវផលប៉ះពាល់ខាងបរិស្ថាន និងសង្គមដែលបណ្តាលមកពីសកម្មភាពវិនិយោគរបស់ពួកគេ ។ កិច្ចខិតខំប្រឹងប្រែងជាក់លាក់នានាគួរត្រូវបានធ្វើ ដើម្បីដោះស្រាយបញ្ហារនាំងខាងភាសា ជាពិសេសចំពោះក្រុមហ៊ុនបរទេសនានា និងនៅពេលដែលពាក់ព័ន្ធនឹងសហគមន៍ជនជាតិដើមភាគតិច ។ ជាវិធានទូទៅ កងកម្លាំងប្រដាប់អាវុធពុំគួរមានវត្តមាននៅអំឡុងពេលនៃការចរចានៅថ្នាក់មូលដ្ឋាននោះទេ ។ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធររដ្ឋាភិបាលនានា (រាប់បញ្ចូលទាំងមន្ត្រីថ្នាក់ខេត្ត និងថ្នាក់ឃុំ) ក៏ដូចជាសហគមន៍នានា គួរជៀសវាងការប្រើប្រាស់អំពើហឹង្សា ។

២៣៤. កិច្ចខិតខំប្រឹងប្រែងទាំងអស់គួរត្រូវបានធ្វើ ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលនៃយន្តការដោះស្រាយវិវាទរបស់គណៈកម្មការសុរិយោដី និងតុលាការ ដើម្បីបង្កើនលទ្ធភាពដល់សហគមន៍នានា ក្នុងការទទួលបានដំណោះស្រាយ

ទាក់ទងនឹងវិវាទដីធ្លី ។ សមត្ថភាព និងឯករាជភាពរបស់ស្ថាប័នតុលាការ គួរត្រូវបានពង្រឹង ដើម្បីឲ្យស្ថាប័ននេះអាចទទួលបាននូវការគោរព និងទំនុកចិត្តពីពលរដ្ឋមូលដ្ឋានរបស់ខ្លួន។ ប្រព័ន្ធតុលាការ មិនគួរត្រូវបានប្រើប្រាស់សម្រាប់ជាយន្តការមួយដើម្បីធ្វើការចោទប្រកាន់សកម្មជនដីធ្លី បុគ្គលទាំងឡាយដែលបានធ្វើការទាមទារដីធ្លីរបស់ពួកគេ អ្នកការពារសិទ្ធិមនុស្ស និង អាជ្ញាធរមូលដ្ឋាន នោះទេ ។

២៣៥. កិច្ចខិតខំប្រឹងប្រែងទាំងអស់គួរត្រូវបានប្រើប្រាស់ដើម្បីឃ្លាំមើលករណីទំនាស់ដីធ្លី នៅក្នុងយន្តការដោះស្រាយវិវាទរបស់គណៈកម្មការសុរិយោដី និងស្ថាប័នតុលាការ ជាក់ស្តែងដូចជា បញ្ហាទំនាស់ផលប្រយោជន៍ អន្តរាគមន៍ខាងនយោបាយ ឬអំពើពុករលួយ ដែលមានពាក់ព័ន្ធនឹងក្រុមហ៊ុនសម្បទាននានា ។ មន្ត្រីរដ្ឋបាល ឬមន្ត្រីតុលាការដែលធ្វើការសម្រេចចិត្ត ដោយផ្អែកលើបុព្វហេតុផ្ទាល់ខ្លួន គួរត្រូវបានហាមឃាត់មិនឲ្យបំពេញតួនាទីនៅក្នុងការវិនិច្ឆ័យសេចក្តី ។

## ឆ. ការពិនិត្យឡើងវិញដោយស្ថាប័នសិទ្ធិមនុស្សនានា និងយន្តការបណ្តឹងអន្តរជាតិផ្សេងៗ

២៣៦. ការប្រើប្រាស់នីតិវិធី និងយន្តការបណ្តឹងតវ៉ាអន្តរជាតិ ក៏ដូចជាស្ថាប័នសិទ្ធិមនុស្សជាតិនានា នៅក្រៅប្រទេស គួរត្រូវបានពិនិត្យគិតគូបន្ថែមទៀតដោយតួអង្គសង្គមស៊ីវិលនានា ដើម្បីនាំយកបណ្តឹងតវ៉ានៃការរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តដោយសហគ្រាសពាណិជ្ជកម្មបរទេស ឬធ្វើប្រតិបត្តិការដោយបរទេស ដែលជាប់ពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សនៅកម្ពុជា (ទោះជាម្ចាស់ភាគហ៊ុនធំ ឬតូចក៏ដោយ) ។ ប្រសិនជាអាច តួនាទីនៃគណៈកម្មការអន្តររដ្ឋាភិបាល ASEAN ស្តីពីសិទ្ធិមនុស្ស អាចត្រូវបានត្រួតពិនិត្យពិច័យបន្ថែមទៀត ។

២៣៧. គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា អាចពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការឃ្លាំមើល ស៊ើបអង្កេត និងធ្វើរបាយការណ៍ស្តីពីការរំលោភសិទ្ធិមនុស្ស នៅក្នុងបរិបទនៃសម្បទានដីនានា ។ របាយការណ៍ទាំងនោះ គួររួមបញ្ចូលអនុសាសន៍ជូនដល់ស្ថាប័នរដ្ឋពាក់ព័ន្ធនានា ព្រមទាំងសហគ្រាសពាណិជ្ជកម្មនានា និងគួរតែធ្វើការផ្សព្វផ្សាយជាសាធារណៈ ។

២៣៨. ដើម្បីផ្តល់លទ្ធភាពត្រួតពិនិត្យបន្ថែមទៀតលើផលប៉ះពាល់សិទ្ធិមនុស្សនៃសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងៗទៀត រដ្ឋាភិបាលគួរតែកោះអញ្ជើញជាអចិន្ត្រៃយ៍នូវយន្តការអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិនានា ឬយ៉ាងហោចណាស់កោះអញ្ជើញអ្នកកាន់អាណត្តិពាក់ព័ន្ធនានា ដែលអាចមានលទ្ធភាពផ្តល់ការវិភាគបានល្អិតល្អន់។ អ្នកដែលពាក់ព័ន្ធជាពិសេសនោះគឺរួមមាន អ្នករាយការណ៍ពិសេសស្តីពីជនជាតិដើមភាគតិច ក្រុមការងារពាណិជ្ជកម្ម (ធុរកិច្ច) និងសិទ្ធិមនុស្ស និងអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិទទួលបានម្ហូបអាហារ លំនៅដ្ឋានសមរម្យ និងការអប់រំ អ្នករាយការណ៍ពិសេសស្តីពីភាពក្រីក្របំផុត សិទ្ធិទទួលបានទឹកពិសារមានសុវត្ថិភាព និងអនាម័យ និងអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិខាងវប្បធម៌ ។

២៣៩. ដោយពិចារណាលើកំណើននៃការរំលោភបំពាននានាទាក់ទិននឹងសេរីភាពបញ្ចេញមតិ និងការប្រមូលផ្តុំនៅក្នុងបរិបទនៃទំនាស់ដីធ្លី ការគិតគូពិចារណាបន្ថែមគួរត្រូវបានផ្តល់ឲ្យដោយស្ថាប័នសិទ្ធិមនុស្សនានា រួមមានអ្នករាយការណ៍ពិសេស និងស្ថាប័នសន្ធិសញ្ញានានា ដើម្បីពិនិត្យពិច័យបន្ថែម និងចងក្រងជាឯកសារនូវការផ្តន្ទាទោសពីបទព្រហ្មទណ្ឌលើសកម្មជនដីធ្លី បុគ្គលទាំងឡាយដែលទាមទារសិទ្ធិលើដីធ្លីរបស់ពួកគេ និងអ្នកការពារសិទ្ធិមនុស្សផ្សេងទៀត ដែលធ្វើការនៅក្នុងវិស័យដីធ្លី ក្នុងគោលដៅផ្តល់ការគាំទ្រ និងការការពារជាបន្ថែមដល់ពួកគេ ។

## ជ.  ការតស៊ូមតិលើសិទ្ធិដីធ្លី និងការអប់រំ

២៤០. អាស្រ័យដោយកំណើននៃការរំលោភសិទ្ធិសេរីភាពបញ្ចេញមតិ និងការប្រមូលផ្តុំ រដ្ឋាភិបាលគួរចាត់វិធានការនានា ដើម្បីអនុវត្តបន្តទៀតនូវច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី រួមមានការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលស្តីពីវិធានណែនាំការអនុវត្តន៍ច្បាប់នេះ ។ ក្រសួងមហាផ្ទៃ គួរបន្តផ្តល់ការណែនាំ និងលើកកំពស់ការយល់ដឹងក្នុ ចំណោមអាជ្ញាធរថ្នាក់ខេត្ត និងរាជធានី រួមទាំងមន្ត្រីអនុវត្តច្បាប់នានា អំពីរបៀបអនុវត្តច្បាប់ស្តីពីការធ្វើបាតុកម្ម ដោយសន្តិវិធី នៅក្នុងលក្ខណៈមួយដែលអនុលោមតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា ។

២៤១. រដ្ឋាភិបាលទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត គួរធានាថាអង្គការសង្គមស៊ីវិល សហគមន៍ និងបណ្តាញសហគមន៍ទាំងឡាយ មានសេរីភាពក្នុងការចូលរួមក្នុងសកម្មភាពនានា ដែលទាក់ទងនឹងការអប់រំសិទ្ធិដីធ្លី ដោយពុំគិតពីកម្មវិធីដំណាលគ្នា ឧទាហរណ៍ កម្មវិធីទាក់ទងនឹងការរៀបចំសម្រាប់ការបោះឆ្នោត និងតាមដានការបោះឆ្នោត នីតិវិធីផ្តល់កម្មសិទ្ធិដីធ្លី និងសកម្មភាពនៃគណៈបក្សនយោបាយនានា។

២៤២. រដ្ឋាភិបាលគួរចូលរួមក្នុងការគាំទ្រសហគមន៍នានា ដើម្បីឲ្យពួកគេកាន់យល់ដឹងតែច្បាស់លាស់អំពីសិទ្ធិនានារបស់ពួកគេ ក្រោមក្របខណ្ឌច្បាប់ជាតិ ដែលគ្រប់គ្រងដីធ្លី និងប្រព័ន្ធសិទ្ធិមនុស្សអន្តរជាតិ ។ កិច្ចការនេះ រួមបញ្ចូលទាំងរបៀបដាក់បណ្តឹងតវ៉ាតាមផ្លូវច្បាប់ និងការធ្វើបណ្តឹងឧទ្ធរណ៍ ។